# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាបុណ្យព្រះនាងម៉ារីឡើងស្ថានបរមសុខនៅផ្សារតូច
# ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៨
*រស់នៅក្នុងរបៀបព្រះនាងម៉ារី*

| |
|---|
| អត្ថបទទី១៖ វវ ១១,១៩ក និង ១២,១-៦ក.១០កខ<br>អត្ថបទទី២៖ ១ករ ១៥,២០-២៧ក<br>ដំណឹងល្អ៖ លក ១,៣៩-៥៦ |

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងគោរពព្រះនាងម៉ារី ដែលព្រះជាម្ចាស់ដែលណែនាំឲ្យឡើងស្ថានបរមសុខ ព្រះនាងម៉ារីជាមនុស្សម្នាក់ ដែលមានមនុស្សជាច្រើនគោរព ស្រឡាញ់ កោតសរសើរ យកជាគំរូ។ ព្រះនាងម៉ារីបានបង្ហាញខ្លួននៅទីក្រុងឡួងដ៍ប្រទេសបារាំង រាល់ឆ្នាំមានរាប់លាននាក់ដែលមកពីពិភពលោកទាំងមូលដើម្បីគោរពព្រះនាងម៉ារី។ ជាពិសេសអ្នកជំងឺ ជនពិការ ដែលពោរពេញដោយសេចក្តីសង្ឃឹមថា ព្រះនាងម៉ារីនឹងព្យាបាលគេឲ្យបានជាសាស្បើយ និងទទួលកម្លាំងសារជាថ្មីនៅក្នុងដួងចិត្ត។ ព្រះនាងម៉ារីនៅទីក្រុងហ្វាទីម៉ា ដែលមនុស្សទូទាំងពិភពលោកទាំងមូលគេទៅគោរព ជាព្រះនាងម៉ារីហ្នឹងដែលបានការពារថែរក្សាសម្តេចប៉ាបយ៉ូហានប៉ូលទីពីរ នៅពេលគេបាញ់គាត់ក្នុងឆ្នាំ១៩៨១។ ព្រះនាងម៉ារីនៅប្រទេសជប៉ុន ពេលរដ្ឋាភិបាលបានបិទផ្លូវមិនឲ្យប្រកាសដំណឹងល្អ មិនឲ្យថ្វាយបង្គំ នៅពេលនោះគ្រីស្តបរិស័ទបានចូលនៅក្នុងព្រៃ បានតស៊ូយ៉ាងខ្លាំងដោយបានអធិដ្ឋានដល់ព្រះនាងម៉ារីរហូត។ នៅប្រទេសវៀតណាម ពេលមានការបៀតបៀនយ៉ាងខ្លាំង ព្រះនាងម៉ារីបានបង្ហាញខ្លួនដើម្បីណែនាំឲ្យគ្រីស្តបរិស័ទពោរពេញដោយសេចក្តីសង្ឃឹម។ សព្វថ្ងៃនៅអរីយក្សេត្រ ពីមួយថ្ងៃទៅមួយថ្ងៃមានគ្រីស្តបរិស័ទនិងមិនមែនគ្រីស្តបរិស័ទ បានទៅថ្វាយបង្គំព្រះនាងម៉ារី ដោយផ្ញើជីវិត ផ្ញើសេចក្តីសង្ឃឹម និងផ្ញើទុក្ខលំបាកទៅព្រះនាងម៉ារី។

មូលហេតុអ្វី នៅពេលយើងធ្លាក់ទឹកចិត្ត នៅពេលមានបញ្ហា នៅពេលមានជំងឺ... ព្រះនាងម៉ារីណែនាំឲ្យយើងមានសេចក្តីសង្ឃឹសាជាថ្មី? ដោយសារព្រះនាងម៉ារីជាម្តាយរបស់ព្រះជាម្ចាស់ និងព្រះនាងម៉ារីជាម្តាយរបស់ព្រះសហគមន៍។ នៅក្នុងក្រុមគ្រួសារមួយ វត្តមានរបស់ម្តាយណែនាំឲ្យយើងមានកម្លាំង ជាម្តាយដែលយកចិត្តទុកដាក់ ជាម្តាយដែលថែរក្សា ជាម្តាយដែលរៀបចំផ្ទះ ជាម្តាយដែលណែនាំអប់រំកូន ជាម្តាយដែលធ្វើឲ្យក្រុមគ្រួសារពោរពេញដោយអំណរសប្បាយនិងកក់ក្តៅ។ នៅក្នុងព្រះសហគមន៍របស់យើង យើងមានព្រះនាងម៉ារីដែលជាម្តាយ ជាម្តាយនៃព្រះសហគមន៍ទាំងមូល ជាម្តាយរបស់ព្រះជាម្ចាស់ និងជាម្តាយរបស់យើងទាំងអស់គ្នា។ នៅពេលយើងជួបជាមួយម្តាយ យើងពោរពេញដោយភាពកក់ក្តៅ យើងពោរពេញដោយអំណរ

សប្បាយ យើងពោរពេញដោយកម្លាំង ពេលយើងជួបជាមួយព្រះនាងម៉ារី យើងក៏មានកម្លាំង មានភាពកក់ក្តៅ មានសេចក្តីសង្ឃឹមជានិច្ច។

ព្រះនាងម៉ារី ជាសាវ័ករបស់ព្រះយេស៊ូមុនគេបង្អស់ ពីថ្ងៃដែលព្រះនាងម៉ារីបានឯកភាពធ្វើជាមាតារបស់ព្រះជាម្ចាស់ដោយទទួលព្រះយេស៊ូនៅក្នុងផ្ទៃពោះរបស់ព្រះនាងផ្ទាល់ ព្រះនាងម៉ារីបានប្រសូតព្រះយេស៊ូ ព្រះនាងម៉ារីបានធ្វើដំណើរជាមួយព្រះយេស៊ូរហូតដល់ក្បែរឈើឆ្កាង ព្រះនាងម៉ារីបានធ្វើជាសាវ័ករបស់ព្រះយេស៊ូ។ ព្រះនាងម៉ារី ជាព្រះមហាក្សត្រីនៃក្រុមគ្រីស្តទូត ដោយសារជាព្រះនាងម៉ារីដែលចាប់ដៃក្រុមគ្រីស្តទូតម្នាក់ៗ ដើម្បីទៅជួបព្រះជាម្ចាស់នៅស្ថានបរមសុខ។ ថ្ងៃនេះ យើងគោរពព្រះនាងម៉ារីឡើងស្ថានបរមសុខមុនគេបង្អស់ យើងមិនបានដឹងងំពីរបៀបដែលព្រះនាងម៉ារីស្លាប់ ប៉ុន្តែនៅក្នុងទីក្រុងយេរូសាឡឹមមានវិសាលវិហារមួយគេគោរពព្រះនាងម៉ារីចូលដេក ក្រោយមកឡើងស្ថានបរមសុខដោយសារព្រះនាងម៉ារីគ្មានជំពាក់បាប។ ព្រះនាងម៉ារី ជាស្ពានរវាងមនុស្សយើងនិងព្រះជាម្ចាស់ រវាងលោកីយ៍នេះនិងស្ថានបរមសុខ។ ព្រះនាងម៉ារីមានបេះដូងដូចយើងជាមនុស្សធម្មតា ប៉ុន្តែព្រះនាងម៉ារីមានជីវិតនៅជាមួយព្រះជាម្ចាស់។ ដូច្នេះពេលយើងរំឭកព្រះនាងម៉ារីជាសាវ័កមុនគេបង្អស់ ណែនាំឲ្យយើងមានកម្លាំងដើម្បីដើរតាមព្រះយេស៊ូតាមរបៀបព្រះនាងម៉ារី។ ព្រះនាងម៉ារីជាម្តាយធម្មតា ធ្វើដំណើរជាមួយកូនរបស់គាត់ ស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ នៅក្បែរឈើឆ្កាងកូនរបស់គាត់ ព្រះនាងម៉ារីជាម្តាយម្នាក់ដែលបានរស់នៅតាមព្រះហឫទ័យព្រះជាម្ចាស់។ ព្រះនាងម៉ារីជាសាវ័ក ជាគ្រីស្តទូតមុនគេបង្អស់ ណែនាំឲ្យយើងមានកម្លាំងដោយសារយើងយល់ថា ដើម្បីដើរតាមព្រះយេស៊ូយើងត្រូវការដើរតាមរបៀបព្រះនាងម៉ារីក្នុងរបៀបសាមញ្ញធម្មតា យើងអាចទៅមុខដើម្បីទទួលជីវិតយ៉ាងពិសេសនៅក្នុងអំណរសប្បាយ និងពោរពេញដោយសេចក្តីសង្ឃឹម។

ព្រះនាងម៉ារីនៅក្បែរឈើឆ្កាង ព្រះនាងម៉ារីមិនបានចោលព្រះយេស៊ូ ពេលយើងឃើញទុក្ខលំបាករបស់ព្រះនាងម៉ារីដែលកំពុងមើលកូនរបស់គាត់ស្លាប់ដោយគ្មានយុត្តិធម៌ ព្រះនាងម៉ារីទៅជាគំរូមួយសម្រាប់យើង។ នៅក្នុងជីវិតរបស់យើង យើងមានទុក្ខលំបាកយ៉ាងច្រើន យើងមានបញ្ហាយ៉ាងច្រើន យើងទទួលការឈឺចាប់យ៉ាងច្រើន ពេលយើងមើលព្រះនាងម៉ារីដែលបានឈឺចាប់យ៉ាងខ្លាំងនៅពេលកូនសោយទិវង្គតលើឈើឆ្កាង យើងទទួលសេចក្តីសង្ឃឹមថែមទៀត ទោះបីព្រះនាងម៉ារីមានទឹកភ្នែកក៏ដោយ ក៏ព្រះនាងម៉ារីបានទុកសេចក្តីសង្ឃឹមនៅក្នុងដួងចិត្តរបស់គាត់ ដោយដឹងថាព្រះជាម្ចាស់ដែលជាព្រះបិតា ដែលលះបង់ចោលព្រះយេស៊ូទេ។ ពិតមែនព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ហើយព្រះនាងម៉ារីជាសាក្សីនៃជីវិតអស់កល្បជានិច្ច រហូតដល់ព្រះនាងម៉ារីទទួលព្រះវិញ្ញាណដ៏វិសុទ្ធរួមជាមួយក្រុមគ្រីស្តទូត នៅថ្ងៃព្រះវិញ្ញាណដ៏វិសុទ្ធយាងមកដើម្បីណែនាំឲ្យយើងពោរពេញដោយសេចក្តីសង្ឃឹម។ ពីសម័យដើមរហូតដល់ពេលនេះ

ព្រះនាងម៉ារីបានថែរក្សាការពារជំនឿរបស់គ្រីស្តបរិស័ទ នៅពេលគ្រីស្តបរិស័ទធ្លាក់ជំនឿ នៅពេលនោះព្រះនាងម៉ារីនៅដើម្បីឲ្យយើងធ្វើដំណើរទៅ។ ព្រះនាងម៉ារី បានណែនាំមនុស្សលោកយ៉ាងច្រើននៅកន្លែងនីមួយៗដែលព្រះនាងម៉ារីបានបង្ហាញខ្លួន ព្រះនាងម៉ារីថា "**សូមកែប្រែចិត្តគំនិត សូមអធិដ្ឋានថែមទៀត សូមរៀបចំខ្លួនដើម្បីទទួលជីវិតអស់កល្បជានិច្ច**"។ ព្រះនាងម៉ារី បានណែនាំឲ្យយើងជាគ្រីស្តបរិស័ទពោរពេញដោយសេចក្តីសង្ឃឹម ដោយសារព្រះនាងម៉ារីរំឭកយើងឲ្យកែប្រែចិត្តគំនិត សូមជឿលើព្រះជាម្ចាស់ សូមជឿលើព្រះយេស៊ូដែលជាកូនរបស់ខ្ញុំ សូមរស់នៅតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដោយមានសេចក្តីស្រឡាញ់នៅក្នុងខ្លួន យកចិត្តទុកដាក់ស្រឡាញ់មនុស្សលោក ដើម្បីឲ្យមនុស្សលោកពោរពេញដោយសេចក្តីសុខសាន្ត។

ថ្ងៃនេះយើងនឹកដល់ព្រះនាងម៉ារី ដែលជាម្តាយរបស់យើង ដែលណែនាំឲ្យយើងមានសេចក្តីសង្ឃឹមសាជាថ្មី យើងនឹកឃើញដល់ព្រះនាងម៉ារីដែលជាសាវ័កមុនគេបង្អស់ ដែលណែនាំឲ្យយើងដើរតាមព្រះយេស៊ូជានិច្ច។ យើងនឹកឃើញដល់ព្រះនាងម៉ារី ដែលនៅក្បែរឈើឆ្កាងពោរពេញដោយទុក្ខលំបាក និងពោរពេញដោយសេចក្តីសង្ឃឹម ដែលណែនាំឲ្យយើងមានសេចក្តីសង្ឃឹមសាជាថ្មី យើងស្តាប់ព្រះសូរសៀងរបស់ព្រះនាងម៉ារីដែលនិយាយដែលយើងម្នាក់ថា "**សូមកែប្រែចិត្តគំនិត សូមជឿលើកូនរបស់ខ្ញុំដើម្បីធ្វើដំណើរតទៅទៀតនៅលើលោកនេះ ដើម្បីរៀបចំផែនដីនេះប្រកបដោយសេចក្តីសង្ឃឹម និងសេចក្តីសុខសាន្ត**"។

យើងអធិដ្ឋានសម្រាប់ព្រះសហគមន៍របស់យើងនៅក្នុងប្រទេសកម្ពុជា សម្រាប់ប្រទេសកម្ពុជារបស់យើង ដើម្បីឲ្យយើងរស់នៅនៅក្នុងសេចក្តីសង្ឃឹមយ៉ាងពិតប្រាកដមែន និងដើម្បីឲ្យយើងធ្វើជាសាក្សីនៃសុខសន្តិភាពនៅក្នុងជីវិត នៅក្នុងក្រុមគ្រួសាររបស់យើង។ ជាពិសេសក្នុងឆ្នាំគ្រួសារ សូមព្រះនាងម៉ារីដែលជាមាតារបស់ព្រះជាម្ចាស់ រួមជាមួយក្រុមគ្រួសារដ៏វិសុទ្ធបំភ្លឺព្រះសហគមន៍របស់យើង ដើម្បីឲ្យយើងរស់នៅក្នុងរបៀបព្រះនាងម៉ារី មានន័យថាដាក់ខ្លួនជាអ្នកក្រខ្សត់ដើម្បីរស់នៅតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ជានិច្ច។ សូមអរព្រះគុណព្រះជាម្ចាស់ ដែលបានប្រទានម្តាយរបស់ព្រះអង្គ ធ្វើជាម្តាយរបស់យើងរៀងៗខ្លួនដែរ៕ អាម៉ែន៕